**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន**

លេខៈ ០៤...រដព.ប្រក...

# ប្រកាស

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋាន របស់អគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

## រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២៣/០១៨ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះ កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋាននានានៃអគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន(រ.ក.ព.) ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់នាយកដ្ឋាន។

## ជំពូកទី២

## រចនាសម្ព័ន្ធនាយកដ្ឋាន

## របស់អគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន

**ប្រការ២ .-**

អគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែនមាននាយកដ្ឋានចំណុះ ដូចខាងក្រោម៖

១- នាយកដ្ឋានគោលនយោបាយនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ មានការិយាល័យចំណុះចំនួន ៣(បី) រួមមាន៖

- ការិយាល័យគោលនយោបាយ
- ការិយាល័យសហប្រតិបត្តិការ
- ការិយាល័យផែនការយុទ្ធសាស្ត្រ។

២- នាយកដ្ឋានអភិវឌ្ឍន៍ព្រំដែនមានការិយាល័យចំណុះចំនួន៣(បី) រួមមាន៖

- ការិយាល័យអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ច
- ការិយាល័យអភិវឌ្ឍន៍សហគមន៍។

៣- នាយកដ្ឋានត្រួតពិនិត្យនិងគាំពារការអភិវឌ្ឍខេត្តជាប់ព្រំដែន មានការិយាល័យចំណុះចំនួន ៣(បី) រួមមាន៖

- ការិយាល័យត្រួតពិនិត្យនិងវាយតម្លៃគម្រោង
- ការិយាល័យគាំពារអាជ្ញាធរមូលដ្ឋាន
- ការិយាល័យប្រជាពលរដ្ឋនិងការអភិវឌ្ឍ។

អង្គការលេខនៃរចនាសម្ព័ន្ធរបស់នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែនរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .-**

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានការិយាល័យ១(មួយ)រូប និងមានអនុប្រធានការិយាល័យមួយចំនួន តាមការចាំបាច់ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី១
## ភារកិច្ចការិយាល័យចំណុះនាយកដ្ឋានគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍

**ប្រការ៤ .-**

ការិយាល័យគោលនយោបាយមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យគោលនយោបាយ
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- ផ្តួចផ្តើមរៀបចំផែនការមេនិងផែនការសកម្មភាពការងារ ដើម្បីកំណត់ចក្ខុវិស័យ ស្នើគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ទ្រទ្រង់និងលើកទឹកចិត្តដល់ការអភិវឌ្ឍតំបន់ព្រំដែន ដើម្បីស្រូបទាញការតាំងទីលំនៅបង្កើតជាសហគមន៍មានសេដ្ឋកិច្ចរស់រវើក ជាប្រយោជន៍ដល់កិច្ចការពារបូរណភាពទឹកដីនិងអធិបតេយ្យជាតិ
- សិក្សា ស្រាវជ្រាវ និងចងក្រងឧត្តមានុវត្តន៍អន្តរជាតិពាក់ព័ន្ធការងារអភិវឌ្ឍន៍តាមតំបន់ព្រំដែន
- ប្រមូល ចងក្រង និងវាយតម្លៃគោលនយោបាយតាមវិស័យ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីកំណត់ឱ្យបាននូវគោលនយោបាយនិងក្របខ័ណ្ឌច្បាប់ ព្រមទាំងក្របខ័ណ្ឌស្ថាប័នដែលត្រូវកែសម្រួលដើម្បីគោលដៅអភិវឌ្ឍន៍តាមតំបន់ព្រំដែន
- សិក្សាស្រាវជ្រាវ ប្រមូល និងចងក្រងទិន្នន័យនិងព័ត៌មានចាំបាច់សម្រាប់កំណត់សក្តានុពលដើម្បីអភិវឌ្ឍនិងបង្កើតម៉ូដែលសេដ្ឋកិច្ច
- ប្រមូល ចងក្រង និងវិភាគផែនការអភិវឌ្ឍន៍និងផែនការវិនិយោគរបស់ខេត្តជាប់ព្រំដែន ដើម្បីជាប្រយោជន៍ដល់ការសម្របសម្រួលធ្វើសមាហរណកម្ម និងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍តំបន់ព្រំដែន ដោយសហការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ
- រៀបចំផែនទីតម្រង់ទិសជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍតំបន់ព្រំដែន ដោយសហការជាមួយអង្គភាពពាក់ព័ន្ធចំណុះ រ.ក.ព. និងក្រសួងស្ថាប័នព្រមទាំងអាជ្ញាធរពាក់ព័ន្ធ
- ចូលរួមជាមួយវិទ្យាស្ថានជាតិកិច្ចការព្រំដែន ដើម្បីផ្សព្វផ្សាយគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអភិវឌ្ឍតំបន់ព្រំដែន
- ចូលរួមតាមដាននិងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនទីតម្រង់ទិសពាក់ព័ន្ធនឹងការអភិវឌ្ឍតំបន់ព្រំដែន ដែលចូលរួមអនុវត្តដោយក្រសួងស្ថាប័ន និងរដ្ឋបាលខេត្តពាក់ព័ន្ធ
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានគោលនយោបាយនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានគោលនយោបាយនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រគល់ជូន។

**ប្រការ៥ .-**

ការិយាល័យសហប្រតិបត្តិការមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យសហប្រតិបត្តិការ
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- ផ្តួចផ្តើមរៀបចំផែនការមេនិងផែនការសកម្មភាពសម្រាប់កសាងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ វិស័យឯកជន គ្រឹះស្ថានស្រាវជ្រាវ និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីកៀរគរហិរញ្ញប្បទាននិងធនធានសហប្រតិបត្តិការ
- ចូលរួមរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍តាមតំបន់ព្រំដែន
- សិក្សា ស្រាវជ្រាវ ចងក្រងលក្ខខណ្ឌនិងគោលការណ៍ហិរញ្ញប្បទានសហប្រតិបត្តិការ ព្រមទាំងហិរញ្ញប្បទានវិនិយោគដែលអនុវត្តដោយធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ និងសហគមន៍អន្តរជាតិ ដើម្បីបង្កើតយន្តការហិរញ្ញប្បទានដែលសមស្របសម្រាប់បម្រើគោលដៅអភិវឌ្ឍន៍តាមតំបន់ព្រំដែន
- ផ្តួចផ្តើមសិក្សាវាយតម្លៃបញ្ហាប្រឈម សក្តានុពលនានាដែលចាំបាច់សម្រាប់លើកកម្ពស់សមាហរណកម្មនិងសុខដុមនីយកម្មផែនការអភិវឌ្ឍន៍ ផែនការវិនិយោគ គម្រោង និងសហគមន៍ ដើម្បីបង្កើតយុទ្ធសាស្ត្រនិងផែនការកៀរគរហិរញ្ញប្បទានពីរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍនិងវិស័យឯកជនទាំងក្នុងស្រុកនិងក្រៅស្រុក
- រៀបចំលើកគម្រោងហិរញ្ញប្បទាន និងកៀរគរធនធាន សម្រាប់គាំទ្រដល់ផែនការអភិវឌ្ឍន៍តាមតំបន់ព្រំដែន
- ពង្រឹងនិងលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋនិងឯកជន ដៃគូអភិវឌ្ឍ សហគមន៍ អង្គការសង្គមស៊ីវិល គ្រឹះស្ថានស្រាវជ្រាវ និងភាគីពាក់ព័ន្ធ ដើម្បីកៀរគរធនធាននិងជំនួយបច្ចេកទេស
- ចូលរួមត្រួតពិនិត្យនិងផ្តល់យោបល់លើគម្រោងវិនិយោគ និងគម្រោងអភិវឌ្ឍន៍តាមតំបន់ព្រំដែន ដើម្បីគោលដៅសមាហរណកម្មនិងសុខដុមនីយកម្មផែនការអភិវឌ្ឍន៍
- ធ្វើការពិគ្រោះយោបល់ ប្រមូលចងក្រងបញ្ហាប្រឈម សំណូមពរនិងអនុសាសន៍នានាដែលដៃគូអភិវឌ្ឍ វិស័យឯកជន សហគមន៍ អង្គការសង្គមស៊ីវិល គ្រឹះស្ថានស្រាវជ្រាវ និងភាគីពាក់ព័ន្ធដទៃទៀតផ្តល់ជូន ដើម្បីកសាងយន្តការលើកកម្ពស់ភាពជាដៃគូនិងសុខដុមនីយកម្ម
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានគោលនយោបាយនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍
- ដឹកនាំសម្របសម្រួលការងាររដ្ឋបាល ការងារបុគ្គលិក និងការងារហិរញ្ញវត្ថុ របស់អគ្គនាយកដ្ឋានគោលនយោបាយ និងអភិវឌ្ឍន៍តំបន់ព្រំដែន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានគោលនយោបាយនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រគល់ជូន។

**ប្រការ៦ .-**

ការិយាល័យផែនការយុទ្ធសាស្ត្រមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យផែនការយុទ្ធសាស្ត្រ
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- សិក្សានិងវិភាគគោលនយោបាយនិងយុទ្ធសាស្ត្រ ដើម្បីបង្កើតផែនការសកម្មភាពនានាដែលចាំបាច់សម្រាប់សម្រេចគោលដៅនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ព្រំដែន
- ចូលរួមរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍តាមតំបន់ព្រំដែន
- សិក្សាវិភាគផែនការអភិវឌ្ឍន៍ ផែនការវិនិយោគនិងគម្រោងពាក់ព័ន្ធនានារបស់ខេត្តជាប់ព្រំដែនដើម្បីគោលដៅលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តនិងការធ្វើសមាហរណកម្មផែនការអភិវឌ្ឍន៍និងវិនិយោគ
- ដឹកនាំរៀបចំបង្កើតយន្តការនានាដែលចាំបាច់សម្រាប់គាំទ្រដល់ការដាក់ឱ្យអនុវត្តផែនការអភិវឌ្ឍន៍តំបន់ព្រំដែនដោយសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ សហគមន៍ និងដៃគូពាក់ព័ន្ធដទៃទៀត ព្រមទាំងអង្គភាពពាក់ព័ន្ធចំណុះ រ.ក.ព.
- សិក្សាស្រាវជ្រាវ ប្រមូលចងក្រងទិន្នន័យ ព័ត៌មាន មតិយោបល់ បញ្ហាប្រឈម សំណូមពរ និងអនុសាសន៍នានា ដើម្បីកែលម្អផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ព្រមទាំងយន្តការគាំទ្រការអនុវត្តនានាឱ្យកាន់តែមានប្រសិទ្ធភាពនិងប្រសិទ្ធផលខ្ពស់
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានគោលនយោបាយនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានគោលនយោបាយនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រគល់ជូន។

## ផ្នែកទី២
## ភារកិច្ចការិយាល័យចំណុះនាយកដ្ឋានអភិវឌ្ឍន៍ព្រំដែន

**ប្រការ៧ .-**

ការិយាល័យអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- ចូលរួមរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍តាមតំបន់ព្រំដែន

- សិក្សា ប្រមូល ចងក្រងព័ត៌មាន និងទិន្នន័យនានាដែលចាំបាច់សម្រាប់រៀបចំកសាងនិងអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងនគរូបនីយកម្មគ្រប់ជ្រុងជ្រោយប្រកបដោយភាពប្រទាក់ក្រឡានិងសមស្របសម្រាប់បម្រើគោលដៅបង្កើតតំបន់សេដ្ឋកិច្ច-ពាណិជ្ជកម្ម និងអភិវឌ្ឍសហគមន៍មួយដែលមានជីវភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌រស់រវើកនៅតាមតំបន់ព្រំដែន
- សិក្សា វាយតម្លៃ សមិទ្ធិលទ្ធភាព និងរៀបចំសំណើកសាងនិង/ឬអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាអាទិ៍ស្ពាន ថ្នល់ ភស្តុភារកម្ម ព្រមទាំងផែនការប្រើប្រាស់ដីធ្លីនិងនគរូបនីយកម្មដែលចាំបាច់សម្រាប់បម្រើគោលដៅការពារបូរណភាពទឹកដី និងអភិវឌ្ឍតំបន់ព្រំដែន ដោយសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ សហគមន៍ និងដៃគូពាក់ព័ន្ធដទៃទៀត ព្រមទាំងអង្គភាពពាក់ព័ន្ធចំណុះ រ.ក.ព.
- ដឹកនាំសម្របសម្រួលការអនុវត្តផែនការកសាងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- សិក្សាវាយតម្លៃហេតុប៉ះពាល់និងផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅតាមបណ្តោយព្រំដែន និង/ឬតំបន់អភិវឌ្ឍន៍តាមព្រំដែន ដោយសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងអង្គភាពពាក់ព័ន្ធចំណុះ រ.ក.ព. ព្រមទាំងលើកសំណើជូនថ្នាក់ដឹកនាំពិនិត្យសម្រេច និងផ្តល់អនុសាសន៍
- ចូលរួមត្រួតពិនិត្យ វាយតម្លៃនិងផ្តល់យោបល់លើគម្រោងវិនិយោគ និងគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ភស្តុភារកម្ម និងនគរូបនីយកម្មតាមបណ្តោយព្រំដែន
- ចូលរួមសិក្សានិងបង្កើតតំបន់ផ្លូវក្រវ៉ាត់ព្រំដែន និងតំបន់ទ្រនាប់ការពារខ្សែបន្ទាត់ព្រំដែន និងតំបន់ផ្សេងៗទៀតដែលបម្រើគោលដៅការពារបូរណភាពទឹកដីនិងអធិបតេយ្យជាតិ ដោយសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធចំណុះ រ.ក.ព.
- ចូលរួមរៀបចំផែនការវិនិយោគ ផែនការថវិកា និងផែនការលទ្ធកម្មសាងសង់និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- ចូលរួមចរចារៀបចំនិងត្រួតពិនិត្យការអនុវត្តគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដោយសហការជាមួយអង្គភាពពាក់ព័ន្ធចំណុះ រ.ក.ព.
- ប្រគល់ទិន្នន័យនិងឯកសារទាក់ទងការងាររៀបចំកសាងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តតាមព្រំដែន ជូនមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន ដើម្បីរក្សាទុក
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានអភិវឌ្ឍន៍ព្រំដែន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានអភិវឌ្ឍន៍ព្រំដែនប្រគល់ជូន។

**ប្រការ៨ .-**

ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ច
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- ចូលរួមរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍តាមតំបន់ព្រំដែន

- សិក្សា ស្រាវជ្រាវ ប្រមូល ចងក្រង និងវិភាគច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងទិន្នន័យនានា ដើម្បីបង្កើតផែនទីតម្រង់ទិស ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពសម្រាប់អភិវឌ្ឍន៍តំបន់ព្រំដែន ដោយបង្កើតឱ្យបាននូវសហគមន៍មួយដែលមានជីវភាពសង្គម វប្បធម៌និងសេដ្ឋកិច្ចរស់រវើក ប្រកបដោយសាមគ្គីភាព បរិយាបន្ន និងសុខដុមនីយភាព
- ប្រមូលចងក្រងទិន្នន័យគម្រោងនានាដែលកំពុងអនុវត្ត និង/ឬត្រូវបង្កើតនៅតាមតំបន់ព្រំដែន
- សិក្សាវាយតម្លៃគម្រោងអភិវឌ្ឍន៍និងគម្រោងវិនិយោគរបស់ខេត្តជាប់ព្រំដែន ព្រមទាំងសក្តានុពលអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម និងសមិទ្ធិលទ្ធភាព ដើម្បីបង្កើតគម្រោងអភិវឌ្ឍន៍ គម្រោងវិនិយោគ និង/ឬគម្រោងពហុបំណងផ្សេងទៀតដែលបម្រើឱ្យគោលដៅរួមជាយុទ្ធសាស្ត្រ និងចក្ខុវិស័យរបស់ រ.ក.ព.
- សិក្សា ស្រាវជ្រាវ ធ្វើទស្សនកិច្ចសិក្សា និងរៀបចំវេទិកាពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន សហគមន៍ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធ ដើម្បីប្រមូលចងក្រងចំណេះដឹង ទិន្នន័យ បញ្ហាប្រឈម សំណូមពរ និងឧត្តមានុវត្តន៍ជាតិ-អន្តរជាតិ ក្នុងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច និងកសាងសហគមន៍ តាមតំបន់ព្រំដែន ព្រមទាំងបង្កើតនិងកែលម្អគោលនយោបាយលើកទឹកចិត្ត និងឧបត្ថម្ភគាំទ្រដល់ការតាំងទីលំនៅរបស់ប្រជាជននិងគម្រោងនានាតាមតំបន់ព្រំដែន
- រៀបចំផែនទីតម្រង់ទិសនិងផែនការមេអភិវឌ្ឍន៍តាមតំបន់ព្រំដែន ដោយសហការជាមួយក្រសួង ស្ថាប័ន សហគមន៍ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ ភាគីពាក់ព័ន្ធ និងអង្គភាពពាក់ព័ន្ធចំណុះ រ.ក.ព.
- បង្កើតម៉ូដែលអភិវឌ្ឍន៍និងគម្រោងអភិវឌ្ឍន៍នានាតាមតំបន់ព្រំដែន ព្រមទាំងយន្តការអនុវត្តដោយសហការជាមួយអង្គភាពពាក់ព័ន្ធចំណុះ រ.ក.ព. និងអាជ្ញាធរពាក់ព័ន្ធ
- កៀរគរធនធាន ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធដើម្បីចូលរួមអភិវឌ្ឍខេត្តជាប់ព្រំដែន
- ដឹកនាំការសិក្សាវាយតម្លៃហេតុប៉ះពាល់និងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច-សង្គម នៃគម្រោងនានាតាមបណ្តោយព្រំដែន ជាអាទិ៍គម្រោងវិនិយោគ គម្រោងបង្កើតនិង/ឬដំឡើងច្រកទ្វារ គម្រោងសម្បទានសង្គមកិច្ច និងគម្រោងពហុបំណងផ្សេងទៀត ដោយមានការចូលរួមសហការពីអង្គភាពពាក់ព័ន្ធចំណុះ រ.ក.ព. និងអាជ្ញាធរពាក់ព័ន្ធ រួចលើកសំណើដោះស្រាយ ជូនរដ្ឋមន្ត្រីទទួលបន្ទុក រ.ក.ព. ពិនិត្យនិងសម្រេច
- ដឹកនាំអនុវត្តផែនការនិងកម្មវិធីឧបត្ថម្ភសហគមន៍ និង/ឬលើកទឹកចិត្តដល់ការអនុវត្តគម្រោងអភិវឌ្ឍន៍និងគម្រោងវិនិយោគ
- ចូលរួមដឹកនាំសម្របសម្រួលការអនុវត្ត ការតាមដាននិងវាយតម្លៃការអនុវត្តគម្រោងតាមតំបន់ព្រំដែន ដោយសហការជាមួយអង្គភាពពាក់ព័ន្ធចំណុះ រ.ក.ព. និងអាជ្ញាធរពាក់ព័ន្ធ
- ចូលរួមបង្កើតនិងកំណត់តំបន់ទ្រនាប់ការពារខ្សែបន្ទាត់ព្រំដែន និងតំបន់បម្រុងទុកសម្រាប់គោលបំណង ជាអាទិ៍កិច្ចការពារបូរណភាពទឹកដី អធិបតេយ្យជាតិ សន្តិសុខជាតិ អភិវឌ្ឍន៍ជាយុទ្ធសាស្ត្រការបង្ការនិងបង្ក្រាបបទល្មើសឆ្លងដែន
- ចូលរួមពិនិត្យនិងផ្តល់យោបល់លើគម្រោងសម្បទានសង្គមកិច្ច គម្រោងអភិវឌ្ឍន៍ និងគម្រោងវិនិយោគនានាតាមតំបន់ព្រំដែន

- ចូលរួមផ្តួចផ្តើមបង្កើត និងកែលម្អយន្តការសម្រាប់ពង្រឹងនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូរវាងរដ្ឋ-ឯកជន សហគមន៍ ដៃគូអភិវឌ្ឍ វិស័យឯកជន គ្រឹះស្ថានស្រាវជ្រាវ និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច ជីវភាពប្រជាជននិងសហគមន៍តាមតំបន់ព្រំដែន
- ធ្វើការសម្របសម្រួលលើកកម្ពស់ការចូលរួមរបស់ប្រជាជន សហគមន៍ និងដៃគូពាក់ព័ន្ធ ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងគម្រោងនានាតាមតំបន់ព្រំដែន
- ចូលរួមត្រួតពិនិត្យនិងផ្តល់យោបល់លើគម្រោងវិនិយោគ អភិវឌ្ឍន៍សហគមន៍តាមបណ្តោយព្រំដែន
- តាមដាននិងវាយតម្លៃជាប្រចាំអំពីការវិវត្តនៃក្របខ័ណ្ឌច្បាប់និងគោលនយោបាយដែលពាក់ព័ន្ធ
- ចូលរួមផ្តល់មតិយោបល់ដោះស្រាយផលប៉ះពាល់នៃគម្រោងនានាតាមតំបន់ព្រំដែន
- ប្រគល់ឯកសារស្តីពីការរៀបចំនិងលទ្ធផលការងារអភិវឌ្ឍន៍សហគមន៍ដែលសម្រេចបាន ជូនមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន ដើម្បីរក្សាទុក
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានអភិវឌ្ឍន៍ព្រំដែន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានអភិវឌ្ឍន៍ព្រំដែនប្រគល់ជូន។

**ប្រការ៩ .-**

ការិយាល័យអភិវឌ្ឍន៍សហគមន៍មានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យអភិវឌ្ឍន៍សហគមន៍
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- ចូលរួមរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍តាមតំបន់ព្រំដែន
- សិក្សា ស្រាវជ្រាវ ប្រមូល ចងក្រង និងវិភាគច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងទិន្នន័យនានា ដើម្បីបង្កើតផែនទីតម្រង់ទិស ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពសម្រាប់អភិវឌ្ឍតំបន់ព្រំដែន ដោយបង្កើតឱ្យបាននូវសហគមន៍មួយដែលមានជីវភាពសង្គម វប្បធម៌ និងសេដ្ឋកិច្ចរស់រវើក ប្រកបដោយសាមគ្គីភាព បរិយាបន្ន និងសុខដុមនីយភាព
- ចូលរួមជាមួយការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ច ធ្វើការសិក្សាវាយតម្លៃគម្រោងអភិវឌ្ឍន៍និងគម្រោងវិនិយោគរបស់ខេត្តជាប់ព្រំដែន ព្រមទាំងសក្តានុពលអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម និងសមិទ្ធិលទ្ធភាព ដើម្បីចូលរួមបង្កើតគម្រោងអភិវឌ្ឍន៍ គម្រោងវិនិយោគ និង/ឬគម្រោងពហុបំណងផ្សេងទៀតដែលបម្រើឱ្យគោលដៅរួមជាយុទ្ធសាស្ត្រ និងចក្ខុវិស័យរបស់ រ.ក.ព.
- សិក្សា ស្រាវជ្រាវ និងធ្វើទស្សនកិច្ចសិក្សា ដើម្បីប្រមូល ចងក្រងចំណេះដឹង ទិន្នន័យ និងឧត្តមានុវត្តន៍ជាតិ អន្តរជាតិ ព្រមទាំងរៀបចំវេទិកាពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន សហគមន៍ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ និងដៃគូពាក់ព័ន្ធនានា ដើម្បីគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច និងកសាងសហគមន៍ដ៏រឹងមាំតាមតំបន់ព្រំដែន
- ផ្តល់ការគាំទ្រដល់ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បីបង្កើតម៉ូដែលអភិវឌ្ឍន៍និងគម្រោងអភិវឌ្ឍន៍នានាតាមតំបន់ព្រំដែន ព្រមទាំងយន្តការអនុវត្ត ដោយសហការជាមួយអង្គភាពពាក់ព័ន្ធដទៃទៀតចំណុះ រ.ក.ព. និងអាជ្ញាធរពាក់ព័ន្ធ

- ដឹកនាំការសិក្សាវាយតម្លៃហេតុប៉ះពាល់និងផលប៉ះពាល់ផ្នែកសង្គមដែលបណ្ដាលពីគម្រោងនានាតាមបណ្ដោយព្រំដែន ជាអាទិ៍គម្រោងវិនិយោគ គម្រោងបង្កើតនិង/ឬដំឡើងច្រកទ្វារ គម្រោងសម្បទានសង្គមកិច្ច និងគម្រោងពហុបំណងផ្សេងទៀត ដោយមានការចូលរួមសហការពីអង្គភាពពាក់ព័ន្ធចំណុះ រ.ក.ព. និងអាជ្ញាធរពាក់ព័ន្ធ រួចលើកសំណើដោះស្រាយជូនរដ្ឋមន្ត្រីទទួលបន្ទុក រ.ក.ព. ពិនិត្យនិងសម្រេច
- ចូលរួមដឹកនាំសម្របសម្រួលការអនុវត្ត ការតាមដាន និងការវាយតម្លៃការអនុវត្តគម្រោងនានាតាមតំបន់ព្រំដែន ព្រមទាំងផលដែលសហគមន៍ទទួលបាន ដោយសហការជាមួយអង្គភាពពាក់ព័ន្ធចំណុះ រ.ក.ព. ក្រសួង ស្ថាប័ននិងអាជ្ញាធរពាក់ព័ន្ធ
- ចូលរួមពិនិត្យនិងផ្ដល់យោបល់លើគម្រោងសម្បទានសង្គមកិច្ចតាមតំបន់ព្រំដែន
- ចូលរួមពិនិត្យនិងផ្ដល់យោបល់លើគម្រោងនានាតាមតំបន់ព្រំដែន
- ចូលរួមផ្ដួចផ្ដើមបង្កើតនិងកែលម្អយន្តការសម្រាប់ពង្រឹងនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការនិងភាពជាដៃគូរវាងរដ្ឋ-ឯកជន សហគមន៍ ដៃគូអភិវឌ្ឍ វិស័យឯកជន គ្រឹះស្ថានស្រាវជ្រាវ និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច ជីវភាពប្រជាជននិងសហគមន៍តាមតំបន់ព្រំដែន
- ធ្វើការសម្របសម្រួលលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍ និងដៃគូពាក់ព័ន្ធដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងគម្រោងនានាតាមតំបន់ព្រំដែន
- ចូលរួមត្រួតពិនិត្យនិងផ្ដល់យោបល់លើគម្រោងវិនិយោគ អភិវឌ្ឍន៍សហគមន៍តាមបណ្ដោយព្រំដែន
- ប្រគល់ឯកសារស្ដីពីការរៀបចំនិងលទ្ធផលការងារអភិវឌ្ឍន៍សហគមន៍ដែលសម្រេចបាន ជូនមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន ដើម្បីរក្សាទុក
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានអភិវឌ្ឍន៍ព្រំដែន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានអភិវឌ្ឍន៍ព្រំដែនប្រគល់ជូន។

## ផ្នែកទី៣
## ភារកិច្ចការិយាល័យចំណុះនាយកដ្ឋានត្រួតពិនិត្យ និងគាំពារការអភិវឌ្ឍខេត្តជាប់ព្រំដែន

**ប្រការ១០ .-**

ការិយាល័យត្រួតពិនិត្យនិងវាយតម្លៃគម្រោងមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យត្រួតពិនិត្យនិងវាយតម្លៃគម្រោង
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- ចូលរួមរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍តាមតំបន់ព្រំដែន
- សិក្សា ស្រាវជ្រាវ ប្រមូល ចងក្រង និងវិភាគគោលនយោបាយ យុទ្ធសាស្ត្រ និងទិន្នន័យនានាដើម្បីបង្កើតផែនទីតម្រង់ទិស ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពសម្រាប់អភិវឌ្ឍ

តំបន់ព្រំដែន ដោយបង្កើតឱ្យបាននូវសហគមន៍មួយដែលមានជីវភាពសង្គម វប្បធម៌និងសេដ្ឋកិច្ចរស់រវើក ប្រកបដោយសាមគ្គីភាព បរិយាបន្ន និងសុខដុមនីយភាព

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងនិងកម្មវិធីអភិវឌ្ឍន៍នានាតាមតំបន់ព្រំដែន
- សិក្សា ស្រាវជ្រាវ វិភាគគម្រោងនានាតាមតំបន់ព្រំដែន ដើម្បីបង្កើតយន្តការថ្មីៗដែលសមស្របសម្រាប់គោលដៅការពារបូរណភាពទឹកដី និងការអភិវឌ្ឍដោយចីរភាពនិងបរិយាបន្ន
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍ ដៃគូអភិវឌ្ឍ វិស័យឯកជន គ្រឹះស្ថានស្រាវជ្រាវ និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីផ្តល់ធាតុចូលសម្រាប់វាយតម្លៃការអនុវត្តគម្រោងនិងលើកសំណើកែលម្អជូនរដ្ឋមន្ត្រី ម្ចាស់គម្រោង និង/ឬដៃគូពាក់ព័ន្ធដទៃទៀត ពិនិត្យនិងសម្រេច
- រៀបចំបែបបទនីតិវិធីក្នុងការពិនិត្យនិងវាយតម្លៃគម្រោង ដោយសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍ ដៃគូអភិវឌ្ឍ វិស័យឯកជន គ្រឹះស្ថានស្រាវជ្រាវ ភាគីពាក់ព័ន្ធដទៃទៀត និងអង្គភាពចំណុះ រ.ក.ព. ដែលពាក់ព័ន្ធ
- ផ្សព្វផ្សាយបែបបទនិងនីតិវិធីក្នុងការវាយតម្លៃគម្រោងដល់ភាគីពាក់ព័ន្ធ
- ចូលរួមសហការជាមួយការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បីប្រមូលចងក្រងទិន្នន័យគម្រោងនានាដែលកំពុងអនុវត្តនិង/ឬត្រូវបង្កើតនៅតាមតំបន់ព្រំដែន
- ប្រគល់ឯកសារស្តីពីការរៀបចំនិងលទ្ធផលការងារត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគម្រោងដែលសម្រេចបាន ជូនមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន ដើម្បីរក្សាទុក
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានត្រួតពិនិត្យនិងគាំពារការអភិវឌ្ឍខេត្តជាប់ព្រំដែន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានត្រួតពិនិត្យនិងគាំពារការអភិវឌ្ឍខេត្តជាប់ព្រំដែនប្រគល់ជូន។

**ប្រការ១១ ._**

ការិយាល័យគាំពារអាជ្ញាធរមូលដ្ឋានមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យគាំពារអាជ្ញាធរមូលដ្ឋាន
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- ចូលរួមរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍តាមតំបន់ព្រំដែន
- សិក្សា ស្រាវជ្រាវ ប្រមូល ចងក្រង និងវិភាគច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងទិន្នន័យនានា ដើម្បីបង្កើតផែនទីតម្រង់ទិស ផែនការយុទ្ធសាស្ត្រ ផែនការមេ និងផែនការសកម្មភាពសម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិនិងអាជ្ញាធរមូលដ្ឋានផ្សេងទៀត ដើម្បីចូលរួមអភិវឌ្ឍតំបន់ព្រំដែននិងការបង្កើតសហគមន៍មួយដែលមានជីវភាពសង្គម វប្បធម៌និងសេដ្ឋកិច្ចរស់រវើក ប្រកបដោយសាមគ្គីភាព បរិយាបន្ន និងសុខដុមនីយភាព
- រៀបចំនិងដឹកនាំអនុវត្តគម្រោង កម្មវិធី និងផែនការគាំពារអាជ្ញាធរមូលដ្ឋានតាមបណ្តាខេត្តជាប់ព្រំដែន ដើម្បីគោលដៅការពារបូរណភាពទឹកដី អភិវឌ្ឍសេដ្ឋកិច្ចនិងសហគមន៍

- កៀរគរធនធាននិងដៃគូអភិវឌ្ឍនានាដើម្បីចូលរួមលើកកម្ពស់សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំនិងដឹកនាំអភិវឌ្ឍខេត្តជាប់ព្រំដែន ដោយឈរលើគោលការណ៍សមាហរណកម្មដើម្បីកំណើនសេដ្ឋកិច្ចនិងការពារបូរណភាពទឹកដីនិងអធិបតេយ្យជាតិ
- អនុវត្តផែនការនិងកម្មវិធីគាំពារអាជ្ញាធរមូលដ្ឋានដោយសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលខេត្តជាប់ព្រំដែន និងអង្គភាពពាក់ព័ន្ធចំណុះ រ.ក.ព.
- ចូលរួមផ្សព្វផ្សាយគោលនយោបាយ ផែនការ កម្មវិធី និងគម្រោងគាំពារដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រមូលចងក្រងសំណូមពរ បញ្ហាប្រឈម ផលប៉ះពាល់ និងតម្រូវការរបស់អាជ្ញាធរមូលដ្ឋាននិងភាគីពាក់ព័ន្ធ ដើម្បីស្នើកែលម្អគោលនយោបាយ ផែនការ កម្មវិធី និងគម្រោងគាំពារដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រគល់ឯកសារស្ដីពីការរៀបចំនិងលទ្ធផលការងារត្រួតពិនិត្យនិងគាំពារការអភិវឌ្ឍខេត្តជាប់ព្រំដែនដែលសម្រេចបាន ជូនមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន ដើម្បីរក្សាទុក
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានត្រួតពិនិត្យនិងគាំពារការអភិវឌ្ឍខេត្តជាប់ព្រំដែន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានត្រួតពិនិត្យនិងគាំពារការអភិវឌ្ឍខេត្តជាប់ព្រំដែនប្រគល់ជូន។

**ប្រការ១២ ._**

ការិយាល័យប្រជាពលរដ្ឋនិងការអភិវឌ្ឍមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យប្រជាពលរដ្ឋនិងការអភិវឌ្ឍ
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- ចូលរួមរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍តាមតំបន់ព្រំដែន
- សិក្សា ស្រាវជ្រាវ ប្រមូល ចងក្រង និងវិភាគច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងទិន្នន័យនានា ដើម្បីបង្កើតផែនទីតម្រង់ទិស ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពគាំទ្រដល់ប្រជាពលរដ្ឋដើម្បីកសាងនិងអប់រំសហគមន៍មួយដែលមានជីវភាពសង្គម វប្បធម៌និងសេដ្ឋកិច្ចរស់រវើក ប្រកបដោយសាមគ្គីភាព បរិយាបន្ន សុខដុមនីយភាព និងការអភិវឌ្ឍដោយចីរភាព
- រៀបចំ បង្កើត និងដឹកនាំសម្របសម្រួលការអនុវត្តកម្មវិធីនិងគម្រោងលើកកម្ពស់ចលនាតាំងទីលំនៅឋានអចិន្ត្រៃយ៍និងការកសាងសហគមន៍តាមតំបន់ព្រំដែន
- ចូលរួមរៀបចំផែនទីតម្រង់ទិស ផែនការមេអភិវឌ្ឍន៍តាមតំបន់ព្រំដែន និងរៀបចំផែនការប្រើប្រាស់ដីធ្លីនិងនគរូបនីយកម្ម
- អនុវត្តផែនការមេនិងផែនការសកម្មភាពការងារពាក់ព័ន្ធនឹងប្រជាពលរដ្ឋ ដោយសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលខេត្តជាប់ព្រំដែន និងអង្គភាពជំនាញរបស់ រ.ក.ព.
- ផ្សព្វផ្សាយគោលនយោបាយ ផែនការ កម្មវិធី និងគម្រោងអភិវឌ្ឍន៍នានាដល់ប្រជាពលរដ្ឋដើម្បីកសាងនិងអភិវឌ្ឍសហគមន៍តាមតំបន់ព្រំដែន

- ទទួលបណ្ដឹងនិងសំណូមពរពីប្រជាពលរដ្ឋ អាជ្ញាធរ ដៃគូអភិវឌ្ឍ វិនិយោគិនជាតិ អន្តរជាតិ និងភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីពិនិត្យនិងផ្ដល់ដំណោះស្រាយ
- ចូលរួមជាមួយវិទ្យាស្ថានជាតិកិច្ចការព្រំដែនដើម្បីអប់រំនិងលើកទឹកចិត្តដល់ប្រជាពលរដ្ឋឱ្យចូលរួម ថែរក្សានិងការពារបូរណភាពទឹកដីនិងអធិបតេយ្យជាតិ
- ប្រគល់ឯកសារស្ដីពីការរៀបចំនិងលទ្ធផលការងារជាមួយប្រជាពលរដ្ឋនិងការអភិវឌ្ឍដែលសម្រេចបាន ជូនមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន ដើម្បីរក្សាទុក
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានត្រួតពិនិត្យនិងគាំពារការអភិវឌ្ឍខេត្តជាប់ព្រំដែន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានត្រួតពិនិត្យនិងគាំពារការអភិវឌ្ឍខេត្តជាប់ព្រំដែនប្រគល់ជូន។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**ប្រការ១៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៤ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន ប្រធានវិទ្យាស្ថានជាតិកិច្ចការព្រំដែន ប្រធានមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន គ្រប់ប្រធាននាយកដ្ឋាន និងអង្គភាពចំណុះរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៤រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ឡាំ ជា**

**កន្លែងទទួល ៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ០២៤ រកព.ប្រក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋាននានារបស់អគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
អង្គការលេខនៃរចនាសម្ព័ន្ធរបស់ការិយាល័យចំណុះនាយកដ្ឋាន នៃអគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន

**អគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន**

- នាយកដ្ឋានគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍
  - ការិយាល័យគោលនយោបាយ
  - ការិយាល័យសហប្រតិបត្តិការ
  - ការិយាល័យផែនការយុទ្ធសាស្ត្រ
- នាយកដ្ឋានអភិវឌ្ឍន៍ព្រំដែន
  - ការិយាល័យអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
  - ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ច
  - ការិយាល័យអភិវឌ្ឍន៍សហគមន៍
- នាយកដ្ឋានត្រួតពិនិត្យនិងគាំពារការអភិវឌ្ឍ ខេត្តជាប់ព្រំដែន
  - ការិយាល័យត្រួតពិនិត្យនិង វាយតម្លៃគម្រោង
  - ការិយាល័យគាំពារអាជ្ញាធរមូលដ្ឋាន
  - ការិយាល័យប្រជាពលរដ្ឋនិង ការអភិវឌ្ឍ